# សេចក្តីថ្លែងការណ៍រួម

## ស្តីពីសកម្មភាពហិង្សារបស់អាជ្ញាធរលើកូដករដែលកំពុងតែធ្វើកូដកម្មនៅ
## ក្រុមហ៊ុន ណាហ្គាវើលដ៍ លីមីធីត

ភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២

យើងខ្ញុំជាសហជីព រួមជាមួយស្ថាប័នសិទ្ធិមនុស្ស ដែលកំពុងធ្វើការដើម្បីលើកកម្ពស់ សិទ្ធិការងារ សិទ្ធិស្ត្រី ជម្រុញឲ្យមានភាពប្រសើរឡើងនូវសមភាពយេនឌ័រ ក្នុងសង្គមកម្ពុជា។ យើងខ្ញុំសូមថ្កោលទោសនូវសកម្មភាពបង្ក្រាបរបស់អាជ្ញាធរទៅលើកូដករស្ត្រីដែលកំពុងតែធ្វើកូដកម្ម ចំពោះវិវាទការងាររវាងកម្មករនិយោជិតណាហ្គាវើលដ៍ និងក្រុមហ៊ុនណាហ្គាវើលដ៍ ក្នុងគោលបំណងទាមទារឲ្យក្រុមហ៊ុនណាហ្គាវើលដ៍យកតំណាងកម្មករនិយោជិត និងសមាជិករបស់ពួកគេចូលធ្វើការងារវិញ ដោយការបញ្ឈប់នេះគឺជាការបញ្ឈប់ដោយភាពអយុត្តិធម៌។

ចំពោះសកម្មភាពបង្ក្រាបយ៉ាងព្រៃផ្សៃ ដើម្បីរារាំងមិនឲ្យកូដករ ទៅធ្វើកូដកម្មនៅក្បែររបងក្រុមហ៊ុនណាហ្គាវើលដ៍ បើទោះជាកូដករ ព្យាយាមអង្វរសុំឲ្យពួកគេ ទៅឈរធ្វើកូដកម្មនៅជិតក្រុមហ៊ុនដែលជាទីកន្លែងដែលពួកគេ គួរត្រូវឈរ និងសម្តែងមតិស្របទៅតាមច្បាប់ស្តីពីការងារ។ ផ្ទុយទៅវិញ ក្រោយពីមានការបង្ក្រាបដោយទង្វើអមនុស្សធម៌ អ្នកនាំពាក្យសាលារាជធានីភ្នំពេញ បានចេញសេចក្តីប្រកាសព័ត៌មានដោយចោទប្រកាន់ថាជាកម្មករនិយោជិតដែលបានប្រើប្រាស់អំពើហិង្សាទៅលើអាជ្ញាធរទៅវិញ នេះជាការបង្ហាញនូវការការពារអ្នកប្រព្រឹត្តអំពើហិង្សា ដោយមិនបានយកអ្នកប្រព្រឹត្តអំពើហិង្សាមកដាក់ទណ្ឌកម្មតាមច្បាប់ដើម្បីព្រមាននោះឡើយ ទង្វើបែបនេះគឺ អាជ្ញាធរបានធ្វើឲ្យបរិយាកាសក្នុងសង្គមកម្ពុជា កាន់តែមានគម្រូរបភាពកើនឡើងនូវការបង្ក្រាបពីអាជ្ញាធរ នៅពេលដែលកម្មករនិយោជិត ប្រើប្រាស់សិទ្ធិជាមូលដ្ឋានរបស់ពួកគេ គឺសិទ្ធិធ្វើកូដកម្ម ដែលធានាដោយអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ៨៧ និង៩៨ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន។

កាលពីល្ងាចថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ រដ្ឋបាលរាជធានីភ្នំពេញបានចេញសេចក្តីប្រកាសព័ត៌មានដោយចោទប្រកាន់ថាហេតុការណ៍នេះបានកើតឡើងដោយសារតែកម្មករនិយោជិតបាន *«ធ្វើការបុកទម្លុះប៉ារាស និងបង្កអំពើហិង្សាមកលើសមត្ថកិច្ច»* ហើយក៏បានគំរាមកំហែងថា *«អាជ្ញាធរមានសមត្ថកិច្ចនឹងចងក្រងកសាងសំណុំរឿងបញ្ជូនទៅស្ថាប័នតុលាការ ដើម្បីនាំជនដៃដល់មកផ្តន្ទាទោសតាមច្បាប់នូវសកម្មភាពបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ប្រើអំពើហិង្សាមកលើអាជ្ញាធរមានសមត្ថកិច្ចក៏ដូចជាប្រមាថមកលើមន្រ្តីរាជការកំពុងបំពេញភារកិច្ច។ »* យើងខ្ញុំសូមបញ្ជាក់ថានេះមិនមែនលើកទីមួយនោះទេដែលកម្មករនិយោជិត ជួបប្រទះនូវអំពើហិង្សាពីអាជ្ញាធរ ហើយរៀងរាល់ពេលដែលកើតមានឡើង សាលារាជធានីភ្នំពេញចេញលិខិតប្រកាសព័ត៌មាន ការពារអ្នកប្រព្រឹត្ត ហើយចោទប្រកាន់មកលើកូដករដែលធ្វើកូដកម្មដោយសន្តិវិធី។ សកម្មភាពបង្ក្រាបនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ មានកូដករស្ត្រីយ៉ាងតិចចំនួន១៧ នាក់បានរងរបួស ទាំងមុខទាំងច្រមុះ និងស្ត្រីពីរនាក់ទៀតបានដួលសន្លប់បន្ទាប់ពីអាជ្ញាធរមួយក្រុមធំបានប្រើប្រាស់ហិង្សាលើកម្មករនិយោជិតដែលកំពុងតែធ្វើកូដកម្ម។ ក្នុងនាមជាអ្នកតំណាងកម្មករនិយោជិតក្នុងវិស័យការងារ រួមជាមួយស្ថាប័នសិទ្ធិមនុស្ស ដែលកំពុងធ្វើការដើម្បីលើកកម្ពស់ សិទ្ធិការងារ សិទ្ធិស្ត្រី ជំរុញឲ្យមានភាពប្រសើរឡើងនូវសមភាពយេនឌ័រ ក្នុងសង្គមកម្ពុជា យើងខ្ញុំទាំងអស់គ្នាថ្កោលទោសរាល់ករណីនៃអំពើហិង្សាទៅលើកម្មករនិយោជិត និង ផ្តន្ទាទោសតាមផ្លូវច្បាប់ទៅលើជនដែលប្រព្រឹត្តអំពើហិង្សាមកលើស្ត្រីកូដករ ដើម្បីលើកកម្ពស់នូវការបញ្ឈប់អំពើហិង្សាលើស្ត្រី និង ជាគម្រូភាពសម្រាប់ការអនុវត្តច្បាប់។

កូដកម្មរយៈពេល៨ខែកន្លងមកនេះ កម្មករនិយោជិតជួបប្រទះនូវសកម្មភាពមានជាអាទិ៍ ៖ ទះកំផ្លៀង ទាត់ ចាប់អូសបោះ ជេរប្រមាថ បៀតបៀនរាងកាយពីអាជ្ញាធរ និង ករណីរលូតកូនក៏មានផងដែរ។ ការប្រើប្រាស់អំពើហិង្សាទៅលើស្ត្រីដែលអនុវត្តសិទ្ធិមូលដ្ឋានរបស់ខ្លួនគឺជាទង្វើមួយដែលមិនស្របតាមគោលការណ៍មូលដ្ឋាននៃសង្គមប្រជាធិបតេយ្យឡើយ។

រាជរដ្ឋាភិបាលមានកិច្ចសន្យាសង្គមចំពោះពលរដ្ឋខ្លួន " មិនទុកនរណាម្នាក់ចោល " និងការពារអ្នករងគ្រោះដោយមិនត្រូវបន្តឲ្យមាននូវការរំលោភបំពានសិទ្ធិជាមូលដ្ឋាន និងភាពអយុត្តិធម៌ចំពោះជនរងគ្រោះនោះឡើយ ។ រដ្ឋាភិបាលត្រូវបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន គឺ គោរព ការពារ និងបំពេញ សិទ្ធិទាំងឡាយដែលផ្តល់ដោយរដ្ឋធម្មនុញ្ញ ច្បាប់ជាតិនិងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងមិនត្រូវរំលោភបំពានជាដាច់ខាត។

សេចក្តីថ្លែងការណ៍រួមនេះចូលរួមគាំទ្រដោយៈ

1. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
2. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
3. សហជីព
4. ទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU)
5. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
6. សហភាពចលនាកម្មករកម្ពុជា(CCW)
7. សម្ព័ន្ធសហជីពចលនាកម្មករ(CUMW)
8. សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា(CDPLA)
9. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
10. សហព័ន្ធសហជីពកម្ពុជាឯករាជ្យ(CITUFED)
11. សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)
12. សម្ព័ន្ធសហជីពកម្មករដើម្បីការងារ(UCL)
13. សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)
14. សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូន (CTWF)
15. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
16. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យឧស្សាហកម្ម (CIWF)
17. សម្ព័ន្ធសហជីពកម្ពុជា (CATU)
18. សហភាពការងារកម្ពុជា (CLC)
19. សហភាពសហជីពកម្ពុជា (CCU)
20. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)
21. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
22. បណ្តាញយុវជនកម្ពុជា (CYN)
23. សហភាពផ្ទះសាមគ្គី (SH)
24. កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
25. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
26. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
27. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
28. អង្គការសមាគមជាងត្នោត(STT)
29. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជា (COMFREL)
30. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(NICFEC)

31. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)
32. អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
33. អង្គការសីលការ(SILAKA)
34. អង្គការសមធម៌កម្ពុជា (EC)
35. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា(CID)
36. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
37. អង្គការសម្ព័ន្ធភាពការពារសិទ្ធមនុស្សកម្ពុជា (CHRAC)
38. អង្គការបន្ទាយស្រី (Banteay Srei)
39. អង្គការ ActionAid កម្ពុជា